# ការរៀបចំ & ការប្រើទឹកដោះសម្រាប់ទារកដោយសុវត្ថិភាព

| | ម្សៅ | ទឹកដោះខាប់ | រួចរាល់ដើម្បីបំបៅ |
|---|---|---|---|
| **ការដាំទឹក**<br>ប្រសិនបើអ្នកជ្រើសរើសដាំទឹក៖<br>... ដាក់ទឹកក្នុងកំសៀវ និង ដាំឲ្យពុះ<br>... ឲ្យទឹកត្រជាក់ត្រឹមសីតុណ្ហភាពបន្ទប់<br>... សាកសីតុណ្ហភាពទឹកលើ កដៃ; មិនក្តៅពេក ឬ ត្រជាក់ពេក? | • | • | — |
| **ការលាយ**<br>... លាងដៃឲ្យបានស្អាត<br>... ដាក់បរិមាណទឹកជាក់លាក់ (យោងទៅផ្លាក)<br>... ដាក់បរិមាណម្សៅ ឬ ទឹកដោះខាប់ជាក់លាក់ (យោងទៅផ្លាក)<br>... ដាក់ស្លាបព្រាចូកដែលស្ងួតចូលកំប៉ុងម្សៅវិញ (សម្រាប់ម្សៅ)<br>... បិទគម្របកំប៉ុង និង ក្រឡុកឲ្យបានសព្វ | • | • | — |
| **ការកម្តៅ**<br>ទឹកដោះសម្រាប់ទារកមិនត្រូវការកម្តៅមុនពេលបំបៅឡើយ។ ប្រសិនបើអ្នកជ្រើសរើសកំដៅវា សូមកម្តៅកំប៉ុងដោយប្រើទឹកហូរក្តៅឧណ្ហៗ ឬ ទឹកដាំពុះ។ ចូរកុំប្រើមីក្រូវេវដើម្បីកម្តៅទឹកដោះសម្រាប់ទារក។ | • | • | • |
| **ការរក្សាទុក**<br> ម្សៅ៖ រក្សាប្រដាប់ទុកម្សៅទឹកដោះសម្រាប់ទារកដោយបិទជិតក្នុងកន្លែងត្រជាក់ស្ងួត មិនមែនក្នុងទូទឹកកកឡើយ។ ប្រើម្សៅនោះក្នុងពេលមួយខែ។<br> ទឹកដោះខាប់៖ រក្សាប្រដាប់ទុកដែលបានបើកនៃទឹកដោះខាប់សម្រាប់ទារកក្នុងទូទឹកកក ក្នុងពេលដល់ទៅ ៤៨ ម៉ោង។ ចូរកុំទុកទឹកដោះខាប់សម្រាប់ទារកដែលបានរៀបចំ ក្នុងសីតុណ្ហភាពបន្ទប់ ហើយចូរកុំបង្កកវា។<br> រួចរាល់ដើម្បីបំបៅ៖ ប្រសិនបើទារកមិនបៅដោយផ្ទាល់ពីកំប៉ុងរួចរាល់មានក្បាលសុដន់ទេ អ្នកអាចរក្សាប្រដាប់ទុកដែលបានបើកនៃទឹកដោះរួចរាល់ដើម្បីបំបៅក្នុងទូទឹកក ក្នុងពេលដល់ទៅ ៤៨ ម៉ោង។ |  |  |  |
| **ចូរកុំប្រើឡើងវិញនូវទឹកដោះសម្រាប់ទារកដែលសល់**<br>ប្រសិនបើកូនរបស់អ្នកមិនអាចបៅអស់ទឹកដោះសម្រាប់ទារកមួយកំប៉ុងក្នុងពេលមួយម៉ោងទេ សូមចោលបរិមាណដែលនៅសល់នោះ។ ចូរកុំរក្សាវាទុកសម្រាប់ពេលក្រោយ។ | • | • | • |

## បណ្ដែសុវត្ថិភាព

### ធ្វើតាមបណ្ដែសុវត្ថិភាពទាំងនេះ ប្រសិនបើអ្នកកំពុងបំបៅទឹកដោះសម្រាប់ទារកដល់កូនរបស់អ្នក។

#### លាងសម្អាតដៃរបស់អ្នក

វាមានសារៈសំខាន់ណាស់ក្នុងការលាងសម្អាតដៃរបស់អ្នកឲ្យស្អាត និង ញឹកញាប់ គ្រប់ពេលដែលអ្នកកាន់កំប៉ុងរបស់កូនអ្នក ឬ គ្រឿងប្រដាប់ប្រដាសម្រាប់កំប៉ុង ឬ ទឹកដោះសម្រាប់ទារក។

#### សីតុណ្ហភាពទឹកដោះសម្រាប់ទារក

តែងពិនិត្យជានិច្ចដើម្បីឲ្យប្រាកដថាទឹកដោះសម្រាប់ទារកនោះមិនក្ដៅពេក។ ទម្លាក់ពីរបីតំណក់ទៅផ្នែកខាងក្នុងនៃកដៃរបស់អ្នក។ ប្រសិនបើវាក្ដៅពេកចំពោះអ្នក វាគឺក្ដៅពេកសម្រាប់ទារកហើយ និង អាចធ្វើឲ្យរលាក។ អ្នកមិនចាំបាច់កម្ដៅទឹកដោះម្ដាយ ឬ ទឹកដោះសម្រាប់ទារកឡើយ។ វេជ្ជបណ្ឌិតជាច្រើនផ្ដល់យោបល់ឲ្យបំបៅក្នុងសីតុណ្ហភាពបន្ទប់។

#### មីក្រូវេវ

មិនត្រូវប្រើមីក្រូវេវដើម្បីរៀបចំ ឬ កម្ដៅទឹកដោះសម្រាប់ទារកឡើយ។ ជំនួសនេះ សូមកាន់កំប៉ុងក្រោមទឹកក្ដៅឧណ្ហៗកំពុងហូរនៅឡាបូ ឬ ដាក់កំប៉ុងក្នុងចានទឹកក្ដៅឧណ្ហៗ។

#### សេចក្ដីណែនាំអំពីការរៀបចំ និង ការបំបៅ

ធ្វើតាមសេចក្ដីណែនាំទាំងអស់ដោយយកចិត្តទុកដាក់ និង ប្រើវិធានជាក់លាក់ដែលបានវាយលើផ្លាក។

#### ពេលបំបៅ

មិនត្រូវអនុញ្ញាតឲ្យកូនរបស់អ្នកកាន់កំប៉ុងបៅដោយគ្មានជំនួយឡើយ។ ចូរកុំទល់ទ្រកំប៉ុង ពីព្រោះការធ្វើដូច្នេះអាចឲ្យទារកឈ្លក់។ ការបំបៅកូនរបស់អ្នកដោយខ្លួនអ្នកក៏ផ្ដល់ឲ្យកូនអ្នកនូវការទំនាក់ទំនង និង ភាពជិតដិតខាងរាងកាយជាច្រើនផងដែរ។

#### ទឹកដោះសម្រាប់ទារកដែលនៅសល់

ចូរកុំប្រើឡើងវិញនូវទឹកដោះសម្រាប់ទារកទាំងឡាយដែលនៅសល់ក្នុងកំប៉ុងដែលកូនរបស់អ្នកមិនអាចបង្ហើយ។ ចោលទឹកដោះសម្រាប់ទារកដែលនៅសល់ទាំងនោះ។ ចូរកុំដាក់វាចូលទៅក្នុងទូទឹកកក ពីព្រោះមេរោគពីមាត់ទារកនឹងលាយជាមួយទឹកដោះសម្រាប់ទារកដែលនៅសល់នោះ និង អាចធ្វើឲ្យទារកឈឺពោះ ឬ រាគ។

#### ទឹកដោះគោ

រង់ចាំរហូតទាល់តែដល់ថ្ងៃកំណើតដំបូងរបស់កូនអ្នកសិន សឹមបំបៅគេដោយទឹកដោះគោ។ កូនរបស់អ្នកត្រូវការអាហារូបត្ថម្ភក្នុងទឹកដោះសម្រាប់ទារកដើម្បីលូតលាស់ និង ធំធាត់ ដែលគ្មានក្នុងទឹកដោះគោ។

#### ទឹកឃ្មុំ

ចូរកុំឲ្យទឹកឃ្មុំទាំងឡាយដល់កូនរបស់អ្នក ក្នុងអំឡុងមួយឆ្នាំដំបូង។ ទឹកឃ្មុំអាចគ្រោះថ្នាក់ណាស់សម្រាប់ទារក និង អាចធ្វើឲ្យគេឈឺខ្លាំង។

## យោបល់របស់វេជ្ជបណ្ឌិតអ្នក

ហៅទូរស័ព្ទទៅវេជ្ជបណ្ឌិត ប្រសិនបើអ្នកមានសំណួរអំពីការរៀបចំ, ការរក្សាទុក ឬ ការបំបៅទឹកដោះសម្រាប់ទារកដល់កូនរបស់អ្នក; ការផ្លាស់ប្ដូរទៅប្រើទឹកដោះសម្រាប់ទារកផ្សេង; ឬ ការបន្ថែមអាហារផ្សេងដល់របបអាហាររបស់កូនអ្នក។

## កំប៉ុងរបស់កូនអ្នក

### ចូរកុំបំបៅកូនរបស់អ្នកនូវរបស់ខាងក្រោមពីកំប៉ុង៖

... ទឹកផ្លែឈើ ឬ សូដា

... ធញ្ញជាតិ ឬ អាហារដទៃដែលលាយជាមួយទឹក, ទឹកដោះ ឬ ទឹកដោះសម្រាប់ទារក

... ទឹកដោះគោ

... ទឹកតែ

ត្រូវការ ដំបូន្មាន ឬ ជំនួយអំពី
ការបំបៅកូនដោយទឹកដោះម្ដាយ?



វាគ្មានបញ្ហាទេក្នុងការ សុំ ជំនួយ៖

ហៅទូរស័ព្ទទៅ វេជ្ជបណ្ឌិត ពេទ្យកុមារ ឬ គិលានុបដ្ឋាករបស់អ្នក » ទាក់ទង អ្នកប្រឹក្សាខាងការបំបៅកូន » ស្វែងយល់អំពី ប្រភពព័ត៌មានជាច្រើនដែលបានចុះផ្សាយលើគេហទំព័រ www.abbottnutrition.com/breastfeeding

Abbott Nutrition

©2010 Abbott Laboratories Inc. មករា ២០១០ 73886 Khmer – IF Preparation